**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**លេខ:** ៨៥៨ សសណ.មឃ

ថ្ងៃ ចន្ទ ១០ រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**
**ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ៖** ករណីរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការធ្វើប្រតិភូកម្មសិទ្ធិអំណាចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទៅឱ្យមន្ទីរ អង្គភាពក្នុងការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនវិនិយោគសមមូល៥លានដុល្លារចុះនៅថ្នាក់រាជធានី ខេត្ត។

**យោង ៖**
-លិខិតលេខ០៣១ របក/គ.ជ.អ.ប ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
-លិខិតលេខ១១៨ ខន/០២៤ សជណ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ របស់ខុទ្ទកាល័យសម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមអភិសន្តិបណ្ឌិតមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានឃើញរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការធ្វើប្រតិភូកម្មសិទ្ធិអំណាចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទៅឱ្យមន្ទីរ អង្គភាពក្នុងការចុះបញ្ជីគម្រោងវិនិយោគដែលមានទុនវិនិយោគសមមូល៥លានដុល្លារចុះនៅថ្នាក់រាជធានី ខេត្ត និងសម្រេចឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមិនទាន់បានធ្វើប្រតិភូកម្ម ត្រូវពន្លឿនការរៀបចំឱ្យបានឆាប់ចប់លើកិច្ចការងារនេះ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអភិសន្តិបណ្ឌិតមេត្តាជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**កែន សត្ថា**

**ចម្លងជូន៖**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ